# របាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ច សម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ២៨ នាក់ ស្រ្តី ០២ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមវេទិកាសាធារណៈចំនួន ០៤ ដង
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការគ្រប់គ្រងបញ្ជីវត្តមាន នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមពិធីក្រុងពាលីបើកការដ្ឋានសាងសង់ស្ពានបេតុងកំពង់រាំង ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ នៅគល់ស្ពានកំពង់រាំង
- ចូលរួមពិធីបើកការដ្ឋានសាងសង់ស្ពានបេតុង នៅកំពង់រាំង ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្រុកឆ្លូង
- ចូលរួមសម្ពោធសាលាបឋមសិក្សាប្រម៉ា ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភូមិប្រម៉ា
- ចូលរួមពិធីបញ្ចុះផ្ទាំងសិលាភ្នំសុពិណកាឡី ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦ នៅវត្តភ្នំសុពិណកាឡី
- ចូលរួមប្រជុំស្តីពីការកែលម្អស្តង់ដារឯកសារដេញថ្លៃ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលាខេត្តក្រចេះ
- ចូលរួមប្រជុំបើក និងវាយតម្លៃឯកសារដេញថ្លៃផ្លូវ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភ្នំពេញ
- ចូលរួមប្រជុំណែនាំដល់ប្រជាពលរដ្ឋ មុខសញ្ញាអ្នកទទួលដី ៩៩៨គ្រួសារ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ នៅស្រុកឆ្លូង
- ចុះពិនិត្យ និងធ្វើការណែនាំដល់ប្រជាពលរដ្ឋក្រុមអនាធិបតេយ្យទន្រ្ទានដី ៩៩៨គ្រួសារ ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅភូមិប្រម៉ា
- ចូលរួមប្រជុំពិភាក្សា ពីការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៦ នៅសាលាខេត្ត
- ចូលរួមប្រជុំពិនិត្យ និងកែសម្រួលលទ្ធផលរបាយការណ៍វេទិកាសាធារណៈឆ្នាំ២០១៥ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលាខេត្ត
- ចូលរួមកិច្ចប្រជុំសាមញ្ញកិច្ចការស្រ្តី ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សា
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី២១ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមប្រជុំប្រចាំឆ្នាំ២០១៥-១៦ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅខេត្តព្រះសីហនុ ។

3. សកម្មភាពតាមការិយាល័យ÷

3.1. **ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**

ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៥១លេខ ក្នុងនោះមាន:

- លិខិតចូលពីអង្គភាពនានាក្រោមន្ទីរ ចំនួន ០៤ លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ១១ លេខ

ខ. ផ្នែកការងារលិខិតចេញ÷

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រៅមន្ទី ចំនួន ៣១ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ១៤ លេខ
- លិខិតចេញទូទៅ (លិខិតអញ្ជើញ និងជូនដំណឹង) ចំនួន ០០ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា ក្រោមឱវាទ ចំនួន ២០ លេខ

គ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **<u>ការិយាល័យផ្លូវជនបទ</u>**÷

- ចុះស្រង់ទិន្នន័យផ្លូវជនបទតាមប្រព័ន្ធ GPS សម្រាប់រៀបចំផែនទីក្នុងខេត្ត បានចំនួន ០៣ ខ្សែ ២០ ១០០ម៉ែត្រ ដែលស្ថិតនៅឃុំកោះប្រែង ស្រុកចិត្របុរី និងឃុំព្រែកប្រសព្វ ឃុំកោះតាស៊ុយ ស្រុកព្រែកប្រសព្វ
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធ GPS សម្រាប់រៀបចំផែនទីក្នុងខេត្ត បាន ០៤ខ្សែ ប្រវែង ៧៦ ៥០០ ម៉ែត្រ ដែលស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំតាម៉ៅ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ
- បញ្ជាក់បច្ចេកទេសមូលនីធិឃុំសង្កាត់ របស់សាលាខេត្តបានចំនួន ០១ គម្រោង ។

3.3. **<u>ការិយាល័យផ្គត់ផ្គង់ទឹកជនបទ</u>**÷

- ចុះពិនិត្យអណ្តូងស្នប់ខូចនៅភូមិច្រណោល (០២ អណ្តូង) ភូមិត្នោត (០១ អណ្តូង) ឃុំថ្មី ស្រុកចិត្របុរី
- ចុះស្រង់ទិន្នន័យបច្ចុប្បន្នភាពអណ្តូងស្នប់ ឃុំកំពង់ចាម ស្រុកសំបូរ ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>**÷ (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>**÷ (គ្មានសកម្មភាព)

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច</u>**÷ (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>**÷ (គ្មានសកម្មភាព)

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>**÷

- លោក ឃាន់ ធន មន្ត្រីការិយាល័យអភិវឌ្ឍន៍ សហគមន៍ បានចូលរួមសិក្ខាសាលា ពិគ្រោះយោបល់លើលទ្ធផលការផ្លាស់ប្តូរនៅក្នុងសហគមន៍ និងការៀបចំផែនការអភិវឌ្ឍន៍ ៣ឆ្នាំ នៅ

ស្រុកឆ្លូង កាលពីថ្ងៃទី ២១-២២ ខែមករា ឆ្នាំ២០១៦ រៀបចំដោយអង្គការ Childfund នៅសណ្ឋាគារលីជី ខេត្តក្រចេះ ។

- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក ហៃ មីត ប្រធានការិយាល័យថៃទាំសុខភាពជនបទ លោក ឡុង អ៊ីន អនុប្រធានការិយាល័យថៃទាំសុខភាពជនបទ បានចូលរួមសិក្ខាសាលា ស្តីពីប្រព័ន្ធផលិតកម្មផលិតស្រា ស កាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៦ រៀបចំដោយរដ្ឋបាលខេត្តក្រចេះ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តក្រចេះ ។

4. <u>ទិសដៅបន្ត</u>÷

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ដើម្បីរៀបចំផែនទីក្នុងខេត្តក្រចេះ ស្ថិតនៅស្រុកចិត្របុរី ស្រុកស្នួល
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធ GPS ដើម្បីរៀបចំផែនទីក្នុងខេត្ត ស្ថិតនៅស្រុកចិត្របុរី ស្រុកស្នួល
- ចុះជួសជុលអណ្តូងនៅភូមិតាពុំ ភូមិរំពុក ឃុំស្វាយជ្រះ ស្រុកស្នួល ។

**ប្រធានមន្ទីរ**